**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

❀❀❀❀❀

**ក្រសួងអប់រំ យុវជន និងកីឡា**

**នាយកដ្ឋានឧត្តមសិក្សា**

**លេខ :....០៩៥............ឧស**

រាជធានីភ្នំពេញ.ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ២០១១

**ប្រធាននាយកដ្ឋានឧត្តមសិក្សា**

**គោរពជូន**

**ឯកឧត្តម លោក លោកស្រី សាកលវិទ្យាធិការ នាយក នាយិកា**

**សាកលវិទ្យាល័យ និងវិទ្យាស្ថាន ក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ** : សំណើសុំអញ្ជើញសាស្ត្រាចារ្យចូលរួមវគ្គបណ្តុះបណ្តាលអំពី " ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) " ។

**យោង** :-លិខិតលេខ ១០០ អយក វ.ប ចុះថ្ងៃ ទី០៦ ខែមករា ឆ្នាំ២០១១ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

-ចំណារលោកជំទាវ អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១១

តតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោក លោកស្រី សាកលវិទ្យាធិការ នាយក នាយិកាជ្រាបថា ក្រសួងអប់រំ យុវជន និងកីឡា បានឯកភាពជាគោលការណ៍ឲ្យមជ្ឈមណ្ឌលឯកសារ-កម្ពុជា រៀបចំបើកវគ្គសិក្សាអំពី ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់គ្រូឧត្តមសិក្សាដែលកំពុងបង្រៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៅតាមគ្រឹះស្ថានឧត្តមសិក្សា ។ វគ្គសិក្សានេះនឹងគ្រោងចាប់ធ្វើពីថ្ងៃទី ២៥ ដល់ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១១ នៅ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ ខ្ញុំសូមឯកឧត្តម លោក លោកស្រី សាកលវិទ្យាធិការ នាយក នាយិកាមេត្តាចាត់តាំងសាស្ត្រាចារ្យដែលបង្រៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋានតាមចំនួនដូចមានក្នុងបញ្ជីឧបសម្ព័ន្ធជូនភ្ជាប់ឲ្យទៅចូលរួម ដោយផ្ញើបញ្ជីឈ្មោះសាស្ត្រាចារ្យទាំងនោះមកខុទ្ទកាល័យ ក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជាចាប់ពីថ្ងៃទី០២ ដល់ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១ តាមការគួរ ។

សូមឯកឧត្តម លោក លោកស្រី សាកលវិទ្យាធិការ នាយក នាយិកាទទួលនូវការគោរពរាប់អានអំពីខ្ញុំ ។

វ័ន្ត-សុខា

**ចម្លងជូន:**

-មជ្ឈមណ្ឌលឯកសារកម្ពុជា

-ខុទ្ទកាល័យក្រសួង អយក ដើម្បីជូនជ្រាប

-ឯកសារ ន.ឧស

(UP)

ទទួល

ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១១